# ដំណោះស្រាយវៃឆ្លាត

## ការធ្វើទំនើបកម្មឌីជីថល លើបណ្តាញចែកចាយថាមពលអគ្គិសនី

DRCs ...

UNIQUE

# DRC-018




info@vpstart.com / sale@vpstart.com | www.vpstart.com | 023 888 167



# DRC-018

## ឧបករណ៍វៃឆ្លាត សម្រាប់ធ្វើទំនើបកម្មលើ Sectionalizer



Schneider Sectionalizer
(RL Series)




## លក្ខណៈពិសេស

- បញ្ជាផ្ដាច់-ភ្ជាប់ Switchgear របស់ Sectionalizer ពីចម្ងាយ
- ទទួលបានព័ត៌មានភ្លាមៗពេលមានភាពមិនប្រក្រតីកើតឡើងនៅលើ Sectionalizer
- អាចត្រួតពិនិត្យមើលស្ថានភាពរបស់ Sectionalizer គ្រប់ពេលវេលា និងគ្រប់ទីកន្លែង



## តើ DRC-018 មានលក្ខណៈពិសេសអ្វីខ្លះ?

DRC-018 ជាអេកូសូលូសិន ដែលត្រូវបានអភិវឌ្ឍឡើងដើម្បីផ្លាស់ប្ដូរការគ្រប់គ្រង Schneider Sectionalizer តាមបែបហត្ថកិច្ច ទៅជាការគ្រប់គ្រងតាមប្រព័ន្ធឌីជីថល។

DRC-018 ជា Smart Grid IoT Device ដែលមានសមត្ថភាពបញ្ជូនព័ត៌មានពីបណ្ដាញចែកចាយទៅកាន់បន្ទប់បញ្ជា ឬទៅកាន់ទូរសព្ទដៃស្មាតហ្វូនរបស់ប្រតិបត្តិករមានដូចជា ព័ត៌មានទូទៅអំពីស្ថានភាពរបស់បណ្ដាញព័ត៌មានអំពីភាពអសកម្មនានា និងលទ្ធភាពក្នុងការបញ្ជាផ្ដាច់ ឬភ្ជាប់ Switchgear របស់ Sectionalizer ពីចម្ងាយបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។



▲ ការភ្ជាប់ DRC-018 ជាមួយ Sectionalizer



▲ DRC-018 ដែលបានធ្វើទំនើបកម្មរួច

## កម្មវិធី PLUM App




## ផ្តល់ព័ត៌មានភ្លាមៗ ពេលមានភាពអសកម្មកើតឡើង




# តើ DRC-018 មានមុខងារពិសេសៗអ្វីខ្លះ?

## ត្រួតពិនិត្យទិន្នន័យ Real-Time (Real-Time Data Monitoring)

ក្រុមការងារអគ្គិសនីអាចត្រួតពិនិត្យមើលអំពីស្ថានភាពរបស់ Sectionalizer ពីចម្ងាយ ដោយគ្រាន់តែប្រើប្រាស់ជាមួយទូរសព្ទដៃស្មាតហ្វូន ឬតាមរយៈប្រព័ន្ធ RPM Grid ដូចជាស្ថានភាព Switchgear កំពុងតែចំហរ ឬភ្ជាប់ (On/Off Position) ជាដើម។

## ផ្តល់ដំណឹងពេលមានភាពមិនប្រក្រតីកើតឡើង (Alarm Notifications)

DRC-018 ផ្តល់ព័ត៌មានដល់ប្រតិបត្តិករភ្លាមៗ នៅពេលដែលមានភាពមិនប្រក្រតីកើតឡើងនៅលើបណ្តាញ។ ព័ត៌មានទាំងនោះមានដូចជា Switchgear ចំហរ (Switchgear Off), ដាច់ប្រភពភ្លើងចូល (MV Absence), និង ការដាច់ទំនាក់ទំនងរវាង Controller និង Switchgear របស់ Sectionalizer ជាដើម (Communication Maintenance)។

### ប្រភេទ ALARM របស់ DRC-018




Switchgear Off | MV Absence | Communication Maintenance

## ផ្តល់ព័ត៌មានអំពីភាពអសកម្មនានា (Abnormal Detection)

ក្រៅពីការផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតីនានានៅលើបណ្តាញ VP.Start ក៏បានបន្ថែមមុខងារសំខាន់ៗមួយចំនួនទៀតដូចជា៖ MCB Switch Off, Switchgear Maintenance, Door Open, និង Battery Low, Gas Low ជាដើម។ មុខងារនេះ ជួយឲ្យក្រុមការងារអគ្គិសនីទទួលបានព័ត៌មានមុនពេលបញ្ហាផ្សេងៗ កើតឡើង ដូចជាធ្វើឲ្យ Sectionalizer គាំងមិនដំណើរការ និងការបញ្ហាផ្តាច់ ឬភ្ជាប់មិនបានជាដើម។

### ALARMS ពេលមានភាពអសកម្មកើតឡើងនៅលើ CONTROLLER




Door Open | Battery Low | MCB Switch Off

### បញ្ជាផ្ដាច់-ភ្ជាប់ Switchgear ពីចម្ងាយ (Remote Control)

ការផ្ដាច់-ភ្ជាប់ Switchgear នៅលើ Schneider Sectionalizer មិនមែនជាបញ្ហាទៀតនោះទេ។ តាមរយៈ DRC-018 ក្រុមការងារអគ្គិសនីអាចបញ្ជាពីចម្ងាយដើម្បីផ្ដាច់ ឬភ្ជាប់ Switchgear ដោយប្រើប្រាស់ត្រឹមតែទូរសព្ទដៃ ឬតាមរយៈប្រព័ន្ធ RPM Grid ឬគ្រាន់តែ Call ក៏អាចបញ្ជាផ្ដាច់-ភ្ជាប់បានដែរ។ មុខងារនេះបានជួយសម្រួលដល់ការធ្វើដំណើរចុះទៅដល់ទីតាំងដោយផ្ទាល់ ដែលបានកាត់បន្ថយការចំណាយថ្លៃប្រតិបត្តិការនានា និងជួយការពារសុវត្ថិភាពក្រុមការងារពីគ្រោះថ្នាក់ផ្សេងៗបានទៀតផង។

### មុខងារ User Events

មុខងារនេះរក្សាទុករាល់សកម្មភាពទាំងអស់របស់ក្រុមការងារដែលបាន ធ្វើប្រតិបត្តិការជាមួយ Sectionalizer ដែលផ្ដល់ភាពងាយស្រួលក្នុងការគ្រប់គ្រងប្រតិបត្តិការទៅលើ Sectionalizer នីមួយៗ។

### មុខងារផែនទី ( Map View )

ក្រុមការងារអាចមើលដឹងពីទីតាំងរបស់ Sectionalizer បានយ៉ាងងាយស្រួលតាមរយៈ Google Map ហើយក៏ងាយស្រួលកំណត់ទីតាំងរបស់ Sectionalizer នៅពេលដែលមានបញ្ហាណាមួយកើតឡើងផងដែរ។

### មុខងារគំនូរប្លង់បច្ចេកទេស ( Single Diagram )

មុខងារនេះផ្ដល់ឱ្យក្រុមការងារអគ្គិសនីនូវរូបភាពតាមបែបគំនូរប្លង់បច្ចេកទេស ដែលងាយស្រួលក្នុងការគ្រប់គ្រង និងកំណត់ទីតាំងរបស់ Sectionalizer ពេលមានបញ្ហាកើតឡើង។

## ដើម្បីគ្រប់គ្រង DRC-018 បានតើត្រូវធ្វើដូចម្ដេច?

### លោកអ្នកអាចគ្រប់គ្រង DRC-018 ដូចខាងក្រោម៖

- ការគ្រប់គ្រងតាមប្រព័ន្ធទូរសព្ទដៃ ដោយប្រើប្រាស់កម្មវិធី PLUM
- ការគ្រប់គ្រងតាមប្រព័ន្ធ RPM Grid នៅក្នុងបន្ទប់បញ្ជា
- បញ្ជាផ្ដាច់-ភ្ជាប់ ឬស្ដាប់ពីស្ថានភាពបណ្ដាញតាមរយៈមុខងារ Call Control។




## ចំណុចពិសេសរបស់ DRC-018 សម្រាប់អាជីវកម្មចែកចាយថាមពលអគ្គិសនី

### ការធ្វើទំនើបកម្មដោយរក្សាបរិក្ខារអគ្គិសនីដែលកំពុងតែប្រើប្រាស់ឱ្យនៅដដែល

ការធ្វើទំនើបកម្មលើ Sectionalizer មិនតម្រូវឱ្យផ្លាស់ប្ដូរបរិក្ខារដែលកំពុងតែប្រើប្រាស់នោះចេញទេ គ្រាន់តែភ្ជាប់ DRC-018 ជាការស្រេច។ សូលូសិននេះ ផ្ដល់លទ្ធភាពដល់ស្ថាប័នផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងការធ្វើទំនើបកម្មដោយចំណាយទុនវិនិយោគតិចបំផុត បើប្រៀបធៀបទៅនឹងការផ្លាស់ប្ដូរថ្មីទាំងស្រុង។

### ការធ្វើទំនើបកម្មរហ័ស

ជាមួយ DRC-018 ការធ្វើទំនើបកម្មចំណាយពេលប្រហែលត្រឹម 30នាទីប៉ុណ្ណោះ គឺអាចធ្វើឱ្យ Sectionalizer ពីធម្មតាទៅជាវ៉ែឆ្លាតបានភ្លាមៗ។

### ងាយស្រួលគ្រប់គ្រង

VP.Start បានបង្កើតប្រព័ន្ធគ្រប់គ្រងដែលផ្ដល់លទ្ធភាពដល់អ្នកប្រើប្រាស់ គ្រប់កម្រិតទាំងអស់។ ប្រព័ន្ធគ្រប់គ្រងនេះបង្កើតឡើងដូចទៅនឹងកម្មវិធីទូរស័ព្ទ ឬកុំព្យូទ័រទូទៅដែលគ្រាន់តែចុចពីរទៅបីឃ្លីកគឺអាចទទួលបានព័ត៌មានពីបណ្ដាញចែកចាយ ឬបញ្ជាផ្ដាច់-ភ្ជាប់ Switchgear របស់ Sectionalizer បានភ្លាមៗ។






## ផ្តល់ផលចំណេញបន្ទាប់ពីការវិនិយោគ (ROI)

ការភ្ជាប់ DRC-018 ជាមួយ Sectionalizer ដែលកំពុងតែប្រើប្រាស់បច្ចុប្បន្ននេះ គឺជាការធ្វើទំនើបកម្មដែលចំណាយទុនវិនិយោគតិចបំផុត បើប្រៀបធៀបទៅនឹងការផ្លាស់ប្តូរថ្មីទាំងស្រុង។

ការកាត់បន្ថយការចំណាយក្រុមការងារចុះទៅប្រតិបត្តិការជាប្រចាំថ្ងៃក៏ជាការសន្សំសំចៃដល់ស្ថាប័នផ្គត់ផ្គង់ថាមពល និងផ្តល់សុវត្ថិភាពដល់ក្រុមការងារផងដែរ។ នេះមិនទាន់រាប់ដល់ការបញ្ជាផ្តាច់ ឬភ្ជាប់ពីចម្ងាយដោយកាត់បន្ថយការដាច់ចរន្តអគ្គិសនីផងទេ។

ទាំងអស់នេះ មិនត្រឹមតែជួយឱ្យគុណភាពនៃការគ្រប់គ្រងបណ្តាញចែកចាយមានភាពប្រសើរឡើង មានភាពរឹងមាំ និងមានស្ថិរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ផលចំណេញត្រឡប់មកវិញលឿនដល់អាជីវកម្មចែកចាយថាមពលអគ្គិសនីផងដែរ។

## ដំណើរការរបស់ប្រព័ន្ធ (System Architecture)



VP.Start

**VP.Start HQ**

Address: #15, Street 604, Sangkat Boeung Kok 2, Khan Toul Kork, Phnom Penh, Cambodia.

**VP.Start Sen Sok Valley Campus**

Address: #29, Street 1946, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia.

VP.Start

www.vpstart.com